# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៧៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១** .-

ត្រូវបានបង្កើតឡើងនូវគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ម.ព.**។

## ជំពូកទី២

## សមាសភាព

**មាត្រា២** .-

**គ.ជ.ម.ព.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៦. តំណាងក្រសួងការពារជាតិ | សមាជិក |
| ៧. តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨. តំណាងក្រសួងផែនការ | សមាជិក |
| ៩. តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១០. តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១១. តំណាងក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១២. តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៣. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១៤. តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៥. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៦. តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៧. តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៨. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩. តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ២០. តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ២១. ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកនិងជាប្រធានលេខាធិការដ្ឋាន |

សមាសភាពជាក់ស្តែងនៃ **គ.ជ.ម.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.ម.ព.

**មាត្រា៣ .-**

**គ.ជ.ម.ព.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូល ចាត់ថ្នាក់ ពិនិត្យឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវរាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃវិធានការមិនមែនពន្ធ ដូចដែលបានកំណត់ដោយអង្គការសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ (UNCTAD)
- ធ្វើបច្ចុប្បន្នកម្ម ផ្សព្វផ្សាយ និងរក្សាទុករាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃវិធានការមិនមែនពន្ធ
- រៀបចំគោលការណ៍ណែនាំអនុវត្ត ប្រសិនបើជាការចាំបាច់ឬធ្វើឱ្យប្រសើរឡើងនូវគោលការណ៍ណែនាំអនុវត្តដែលមានស្រាប់ ដើម្បីធានាថាការអនុវត្តមិនរឹតត្បិតជាងសេចក្តីត្រូវការ
- វាយតម្លៃនិងកែសម្រួលឡើងវិញនូវវិធានការមិនមែនពន្ធ ដើម្បីកាត់បន្ថយជាអតិបរមា ការរឹតត្បិតទៅលើការធ្វើពាណិជ្ជកម្មនិងវិនិយោគ
- កំណត់សមាសភាពរឹតត្បិតដែលមិនចាំបាច់នៃវិធានការមិនមែនពន្ធ និងលើកសំណើសុំកែប្រែឬលុបសមាសភាពទាំងនោះជូនរាជរដ្ឋាភិបាល ដើម្បីធានាអនុលោមភាពជាមួយបណ្តាកិច្ចព្រមព្រៀងតំបន់និងអន្តរជាតិ
- ជូនព័ត៌មានអំពីវិធានការមិនមែនពន្ធទៅអង្គការពាណិជ្ជកម្មពិភពលោកតាមរយៈក្រសួងពាណិជ្ជកម្មនិងទៅលេខាធិការដ្ឋានអាស៊ាន តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- វាយតម្លៃអំពីការលំបាកនានាក្នុងកិច្ចដំណើរការរបស់ស្ថាប័ននិងគៀរគរធនធានហិរញ្ញវត្ថុដើម្បីពង្រឹងសមត្ថភាពស្ថាប័ននិងមន្ត្រី
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធានាសង្គតិភាព ប្រសិទ្ធភាពនិងពង្រឹងកិច្ចសហប្រតិបត្តិការ
- ទទួលនិងប្រើប្រាស់ហិរញ្ញប្បទានពីបណ្តាប្រទេសដទៃទៀត អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវវិធានការមិនមែនពន្ធ
- ផ្តល់អនុសាសន៍តាមការចាំបាច់និងរៀបចំរបាយការណ៍បូកសរុបការងារប្រចាំឆ្នាំអំពីវឌ្ឍនភាពការងារជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ម.ព.

**មាត្រា៤ .-**

**គ.ជ.ម.ព.** ត្រូវរៀបចំនីតិវិធីប្រតិបត្តិនិងផែនការការងារប្រចាំឆ្នាំរបស់ខ្លួន។

**មាត្រា៥ .-**

**គ.ជ.ម.ពា.** ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួនដូចមានចែងក្នុងមាត្រា៣និងមាត្រា៤ខាងលើ។ នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាននៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបំពេញមុខងារជាលេខាធិការដ្ឋានរបស់ **គ.ជ.ម.ពា.**។

លេខាធិការដ្ឋាន **គ.ជ.ម.ពា.** អាចស្នើសុំយោបល់ពីក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬស្ថាប័ន អង្គភាពប្រឹក្សាច្បាប់ផ្សេងទៀត អំពីសេចក្តីព្រាងសំណើសុំកែប្រែវិធានការមិនមែនពន្ធឬលុបបំបាត់វិធានការមិនមែនពន្ធ។

ក្រសួង ស្ថាប័ននីមួយៗដូចបានរៀបរាប់ខាងលើ ត្រូវកំណត់ចំណុចទំនាក់ទំនង និងត្រូវជូនព័ត៌មានអំពីការចាត់នេះ ជាលាយលក្ខណ៍អក្សរមកលេខាធិការដ្ឋាននៃ **គ.ជ.ម.ពា.**។ រាល់ការផ្លាស់ប្តូរចំណុចទំនាក់ទំនងត្រូវជូនព័ត៌មានជាបន្ទាន់និងជាលាយលក្ខណ៍អក្សរ មកលេខាធិការដ្ឋាននៃ **គ.ជ.ម.ពា.**។

**មាត្រា៦ .-**

ក្រសួង ស្ថាប័នដែលរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការមិនមែនពន្ធអាចអញ្ជើញតំណាងលេខាធិការដ្ឋានឱ្យចូលរួមរៀបចំ ហើយត្រូវបញ្ជូនសេចក្តីព្រាងនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះមក **គ.ជ.ម.ពា.** ដើម្បីធានាអនុលោមភាពទៅនឹងច្បាប់ជាធរមានរបស់កម្ពុជានិងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ដែលកម្ពុជាជាភាគី។ **គ.ជ.ម.ពា.** ត្រូវពិនិត្យនិងឆ្លើយតបទៅសាមីក្រសួង ស្ថាប័នក្នុងរយៈពេលយ៉ាងយូរ៩០(កៅសិប)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ចំពោះច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានានៃវិធានការមិនមែនពន្ធដែលមានស្រាប់ **គ.ជ.ម.ពា.** ត្រូវត្រួតពិនិត្យឡើងវិញដើម្បីធានាអនុលោមភាពទៅនឹងកាតព្វកិច្ច ក្រោមកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ ដែលកម្ពុជាជាភាគី។ ក្នុងករណីចាំបាច់ **គ.ជ.ម.ពា.** អាចស្នើឱ្យក្រសួង ស្ថាប័នសាមីត្រួតពិនិត្យនិងកែសម្រួលឡើងវិញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានានៃវិធានការមិនមែនពន្ធដែលរកឃើញថាមិនមានអនុលោមភាពទៅនឹងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ដែលកម្ពុជាជាភាគី។

ក្នុងករណីបន្ទាន់និងមានភស្តុតាងពេញលេញ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានានៃវិធានការមិនមែនពន្ធអាចអនុវត្តបានដោយក្រសួងសាមីជាមុននិងត្រូវធ្វើការត្រួតពិនិត្យដោយ **គ.ជ.ម.ពា.** ជាក្រោយ។ ក្នុងករណីនេះ ក្រសួងសាមីដែលបានអនុម័តវិធានការដូចខាងលើ ត្រូវជូនព័ត៌មានអំពីការអនុវត្តជាបន្ទាន់ មក **គ.ជ.ម.ពា.**។

**មាត្រា៧ .-**

សមាជិកនៃ **គ.ជ.ម.ពា.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធាន **គ.ជ.ម.ព.** ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានត្រូវអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួស។

ប្រធាន **គ.ជ.ម.ព.** អាចអញ្ជើញអ្នកជំនាញនិងតំណាងក្រសួង ស្ថាប័នដែលមិនមែនជាសមាជិកនៃ **គ.ជ.ម.ព.** ចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៨ .-**

**គ.ជ.ម.ព.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំ។

ក្នុងករណីចាំបាច់ **គ.ជ.ម.ព.** អាចប្រជុំជាវិសាមញ្ញ តាមការកោះអញ្ជើញរបស់ប្រធាន។

**មាត្រា៩ .-**

**គ.ជ.ម.ព.** មានសិទ្ធិប្រើត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាននិងមូលនិធិ

**មាត្រា១០ .-**

ការចំណាយសម្រាប់ដំណើរការ **គ.ជ.ម.ព.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.ជ.ម.ព.** មានសិទ្ធិទទួលនិងចាត់ចែង ប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ